# ការកែលម្អខ្លួនក្នុងនាមជាគ្រូបង្រៀនដូចជាព្រះគ្រីស្ទ — ការវាយតម្លៃផ្ទាល់ខ្លួន

ក្នុងនាមជាគ្រូបង្រៀន យើងគួរតែវាយតម្លៃពីភាពខ្លាំង និងភាពខ្សោយរបស់យើងជាទៀងទាត់ ដើម្បីយើងអាចជួយឲ្យ សិស្សស្ថាបនាសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែក្លាយឲ្យកាន់តែដូចជាទ្រង់ ។ សកម្មភាពដូចខាងក្រោមអាចជួយអ្នកឲ្យអនុវត្តគោលការណ៍នានានៃការបង្រៀនដូចជាព្រះគ្រីស្ទ ។ សូមពិចារណាថាតើសេចក្តីថ្លែងការណ៍នីមួយៗខាងក្រោមនេះពិពណ៌នាអំពីអ្នកក្នុងនាមជាគ្រូបង្រៀនបានល្អប៉ុណ្ណា ។ សូមជ្រើសរើសចម្លើយដែលសមរម្យបំផុតសម្រាប់សេចក្តីថ្លែងការណ៍នីមួយៗ ៖ ( ១ ) កម្រណាស់ ( ២ ) ពេលខ្លះ ( ៣ ) ជាញឹកញាប់ ( ៤ ) ស្ទើរតែគ្រប់ពេល ។

បន្ទាប់មក នៅពេលបានដឹកនាំដោយព្រះវិញ្ញាណ សូមជ្រើសរើសចំណុចមួយចំនួនដែលអ្នកចង់កែលម្អប្រកបដោយការអធិស្ឋាន ។ សូមដាក់គោលដៅមួយចំនួន ហើយប្រើធនធាននេះដើម្បីជួយអ្នកកែលម្អ ។

## ផ្តោតលើព្រះយេស៊ូវគ្រីស្ទ

__ខ្ញុំបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទមិនថាខ្ញុំកំពុងបង្រៀនអ្វីនោះទេ ។

__ខ្ញុំគូសបញ្ជាក់ពីគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ។

__ខ្ញុំជួយសិស្សឲ្យស្គាល់សេចក្តីស្រឡាញ់ ព្រះចេស្តា និងសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ។

__ខ្ញុំជួយសិស្សឲ្យពង្រឹងនូវទំនាក់ទំនងរបស់ពួកគេ ជាមួយព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។

__ខ្ញុំជួយសិស្សឲ្យខិតខំព្យាយាមដោយឯកឯងដើម្បីប្រែក្លាយកាន់តែដូចជាព្រះយេស៊ូវគ្រីស្ទ ។

## ស្រឡាញ់មនុស្សដែលអ្នកបង្រៀន

__ខ្ញុំខិតខំព្យាយាមមើលទៅសិស្សតាមរបៀបដែលព្រះទតមើលពួកគេ ។

__ខ្ញុំស្វែងយល់ដើម្បីស្គាល់មនុស្សដែលខ្ញុំបង្រៀន—ដើម្បីយល់ពីស្ថានភាព តម្រូវការ និងភាពខ្លាំងរបស់ពួកគេ ។

__ខ្ញុំអធិស្ឋានឲ្យសិស្សតាមឈ្មោះ ។

__ខ្ញុំបង្កើតបរិយាកាសសុវត្ថិភាពមួយ ដែលសិស្សគ្រប់គ្នាទទួលបានការគោរព និងដឹងថាការរួមចំណែករបស់ពួកគេត្រូវបានឲ្យតម្លៃ ។

__ខ្ញុំរកវិធីសមរម្យដើម្បីបង្ហាញពីសេចក្តីស្រឡាញ់របស់ខ្ញុំ ។

## បង្រៀនដោយព្រះវិញ្ញាណ

__ខ្ញុំរៀបចំខ្លួនរបស់ខ្ញុំខាងវិញ្ញាណដើម្បីបង្រៀន ។

__ខ្ញុំឆ្លើយតបទៅនឹងការបំផុសគំនិតខាងវិញ្ញាណអំពីតម្រូវការរបស់សិស្ស ។

__ខ្ញុំបង្កើតបរិយាកាស និងឱកាសឲ្យសិស្សទទួលការបង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ។

__ខ្ញុំជួយសិស្សឲ្យស្វែងរក ស្គាល់ និងធ្វើតាមវិវរណៈផ្ទាល់ខ្លួន ។

__ខ្ញុំថ្លែងទីបន្ទាល់ជាញឹកញាប់ ហើយខ្ញុំលើកទឹកចិត្តសិស្សឲ្យចែកចាយអារម្មណ៍ បទពិសោធន៏ និងទីបន្ទាល់របស់ពួកគេ ។

## បង្រៀនគោលលទ្ធិ

__ខ្ញុំរៀនគោលលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទសម្រាប់ខ្លួនខ្ញុំផ្ទាល់ ។

__ខ្ញុំបង្រៀនចេញពីបទគម្ពីរ និងប្រសាសន៍របស់ពួកព្យាការីថ្ងៃចុងក្រោយ ។

__ខ្ញុំជួយសិស្សឲ្យស្វែងរក ស្គាល់ និងយល់ពីសេចក្តីពិតនៅក្នុងបទគម្ពីរ ។

__ខ្ញុំផ្តោតលើសេចក្តីពិតដែលដឹកនាំទៅរកការសន្ទនា និងកសាងសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។

__ខ្ញុំជួយសិស្សឲ្យស្វែងរកភាពពាក់ព័ន្ធផ្ទាល់ខ្លួននៅក្នុង គោលលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ។

## អញ្ជើញឲ្យមានការរៀនសូត្រយ៉ាងឧស្សាហ៍ព្យាយាម

__ខ្ញុំជួយសិស្សឲ្យទទួលខុសត្រូវលើការរៀនសូត្ររបស់ពួកគេ ។

__ខ្ញុំលើកទឹកចិត្តសិស្សឲ្យមកស្គាល់ព្រះអង្គសង្គ្រោះ តាមរយៈការសិក្សាដំណឹងល្អជារៀងរាល់ថ្ងៃ ។

__ខ្ញុំអញ្ជើញសិស្សឲ្យត្រៀមខ្លួនរៀនសូត្រ ។

__ខ្ញុំលើកទឹកចិត្តសិស្សឲ្យចែកចាយសេចក្តីពិតដែលពួកគេកំពុងរៀន ។

__ខ្ញុំអញ្ជើញសិស្សឲ្យរស់នៅតាមអ្វីដែលពួកគេកំពុងរៀន ។